**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 22-Sep-2015, 15:55
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរ ឆាក់ឆង សំ សិទ្ធី**

---

**<u>ដាក់ដោយ</u>៖**

**<u>សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី</u>៖**

ពេជ អង្គ

Marie GUIRAUD

**<u>សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>៖**

ជេត វណ្ណលី

ហុង គីមសួន

គីម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

**<u>នៅចំពោះមុខ</u>៖**

**<u>ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល</u>៖**

ចៅក្រម គង់ ស្រីម ប្រធាន

ចៅក្រម A. KLONOWIECKA-MILART

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម C.N. JAYASINGHE

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម យ៉ា ណារិន

ចៅក្រម Florence Ndepele Mwachande MUMBA

**<u>ផ្ញើជូន</u>៖**

Original EN: 01141068-01141082

ស៊ិន សុវ៉ន

សំ សុគង់

វ៉ែន ពៅ

ទី ស្រ៊ីនណា

Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI

**<u>ការិយាល័យសហព្រះរាជអាជ្ញា៖</u>**

ជា លាង

Nicholas KOUMJIAN

**<u>ជនជាប់ចោទ៖</u>**

នួន ជា

ខៀវ សំផន

**<u>សហមេធាវីការពារក្តី៖</u>**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

**<u>មេធាវីប្រចាំការ៖</u>**

ទូច វរល័ក្ស

Calvin SAUNDERS

**<u>សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

Olivier BAHOUGNE
Patrick BAUDOUIN
Beini YE

## I. សេចក្តីផ្តើម

1. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមឆ្លើយតបចំពោះសំណើរបស់មេធាវីការពារក្តីនួន ជា សុំបំពេញកិច្ចស៊ើបសួរ ចំពោះហេតុការណ៍ដែលបានរៀបរាប់ នៅក្នុងសក្ខីកម្មរបស់ សំ សិទ្ធី ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥[1]។

2. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានចំណាប់អារម្មណ៍ក្នុងការឆ្លើយតបទៅនឹង អង្គសេចក្តីរបស់សំណើនេះ នៅពេលដែលសំណើនេះប៉ះពាល់ដល់តុល្យភាពនៃសិទ្ធិរបស់ភាគីនានា រួមទាំងភាគីដើមបណ្តឹងរដ្ឋប្បវេណីផង។ ហេតុដូច្នេះសហមេធាវីនាំមុខ សូមធ្វើការឆ្លើយតបចំពោះអង្គសេចក្តីនៃសំណើ ប៉ុន្តែសូមគោរពតាមសេចក្តីបង្គាប់របស់អង្គជំនុំជម្រះតុលាការកំពូលលើដំណោះស្រាយដែលត្រូវស្នើសុំ។

## II. ប្រវត្តិនីតិវិធី

3. នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៨ សំ សិទ្ធី ត្រូវបានស្តាប់ចម្លើយដោយសហចៅក្រមស៊ើបអង្កេតអំពីហេតុការណ៍ដែលបានកើតឡើងក្នុង របបកម្ពុជាប្រជាធិបតេយ្យ[2]។ កំណត់ហេតុស្តាប់ចម្លើយរបស់ក.ស.ច.ស ត្រូវបានផ្តល់ជូនភាគីនានា នៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៩[3]។

4. នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៣ មេធាវីការពារក្តីនួន ជា បានស្នើដល់អង្គជំនុំជម្រះសាលាដំបូងឲ្យកោះហៅសំ សិទ្ធី ធ្វើជាសាក្សីមួយរូបដែលពាក់ព័ន្ធនឹងការចោទប្រកាន់ ពីគោលនយោបាយនៃការកំណត់គោលដៅ ចំពោះអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ[4]។ នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា៖

> សេចក្តីសម្រេចរបស់នួន ជា ក្នុងការមិនស្នើសុំសាក្សីទាំងនេះ កាលពីពេលមុន បើទោះបីជាខ្លួនទទួលបានការជូនដំណឹងថា កំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងនេះ អាចត្រូវបានទទួលយកជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ តាំងពីខែ មេសា ឆ្នាំ ២០១១ក៏ដោយ មិនមែនជាការយកចិត្តទុកដាក់

---

[1] សំណើសុំបំពេញកិច្ចស៊ើបសួរ ចំពោះហេតុការណ៍ដែលបានរៀបរាប់ ក្នុងសក្ខីកម្មរបស់ សំ សិទ្ធី, ឯកសារ **F28**, ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ (“សំណើរ”)។

[2] សូមមើល ឯកសារ E3/5201 កំណត់ហេតុស្តាប់ចម្លើយសាក្សី សំ សិទ្ធី។

[3] ឯកសារ E3/5201, ទំព័រ ១។

[4] សំណើសុំកោះហៅសាក្សី ពាក់ព័ន្ធការចោទប្រកាន់ពីគោលនយោបាយ នៃការកំណត់គោលដៅចំពោះអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ, ឯកសារ **E291/2**, ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៣, កថាខណ្ឌ ៥។ សូមមើលបន្ថែម ឧបសម្ព័ន្ធ ក៖ សាក្សីដែលត្រូវបានដកស្រង់សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ពាក់ព័ន្ធការចោទប្រកាន់ពីគោលនយោបាយ ក្នុងការកំណតគោលដៅលើអ្នករដ្ឋការ និងទាហានលន់ នល់ ដើម្បីសម្លាប់, ឯកសារ **E291/2.1**។

គ្រប់គ្រាន់ក្នុងការស្វែងរក និងស្នើសុំភស្តុតាងនេះទេ ជាពិសេសក្នុងដំណាក់កាលចុងក្រោយ នៃការជំនុំជម្រះនេះ។ ហេតុដូច្នេះ នួន ជា មិនបានបំពេញតាមលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងនោះទេ។ អង្គជំនុំជម្រះសម្រេចបដិសេធលើសំណើនេះ។

៣៩. ... ក្នុងករណីដែលកំណត់ហេតុស្តាប់ចម្លើយសាក្សី ដូចជាចម្លើយសាក្សីទាំងនេះជាដើម បានបំពេញតាមលក្ខខណ្ឌនានានោះ អង្គជំនុំជម្រះបានសម្រេចរួចហើយថា ដើម្បីជាប្រយោជន៍នៃយុត្តិធម៌ និងកិច្ចដំណើរការនីតិវិធីឆាប់រហ័ស ចម្លើយទាំងអស់នេះត្រូវទទួលយក ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ ដូច្នេះគឺអនុញ្ញាតឲ្យអង្គជំនុំជម្រះលែងត្រូវការ វត្តមានរបស់អ្នកផ្តល់ចម្លើយនៅចំពោះមុខតុលាការ”[5]។

5. នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ បានចេញសាលក្រមរបស់ខ្លួន ប្រឆាំងសហជនជាប់ចោទ[6]។ កំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី ត្រូវបានដាក់នៅជើងទំព័រ ក្នុងកថាខណ្ឌ ៥១១ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងពីរដង។ ការបញ្ចូលទាំងពីរលើកនេះ ត្រូវបានបញ្ជាក់នៅផ្នែកខាងក្រោម[7]។

6. នៅពេលពិភាក្សាពីភស្តុតាងទៅលើអង្គហេតុ ពាក់ព័ន្ធការប្រព្រឹត្តិចំពោះអ្នករដ្ឋការ និងទាហានរបបសាធារណរដ្ឋខ្មែរ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅរក កំណត់ហេតុស្តាប់ចម្លើយ សំ សិទ្ធី ម្តង ដើម្បីឈានទៅធ្វើសេចក្តីសន្និដ្ឋានលើអង្គហេតុថា៖

“នៅប៉ុន្មានថ្ងៃបន្ទាប់ពីជម្លៀស ខ្មែរក្រហមបានប្រកាសតាមវិទ្យុ និងតាមមីក្រូនៅតាមកន្លែងជាច្រើនក្នុងទីក្រុងភ្នំពេញថា អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវចូលបង្ហាញខ្លួន បង្ហាញពីឋានៈ តួនាទី កាលពីមុនរបស់ខ្លួន និងត្រឡប់ទៅទីក្រុងភ្នំពេញវិញដើម្បីសហការ ឬ ចូលរួមជាមួយកងទ័ពខ្មែរក្រហម”[8]។

---

[5] សេចក្តីសម្រេចលើការជំទាស់ចំពោះ ភាពអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយសាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងប្រតិចារឹកសំណុំរឿង ០០១ ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី, ឯកសារ **E299**, ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣, កថាខណ្ឌ ៣៨ ដល់៣៩។

[6] សាលក្រមសំណុំរឿង ០០២/០១, ឯកសារ **E313**, ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤, (“សាលក្រមអង្គជំនុំជម្រះសាលាដំបូង”)។

[7] ការបង្ហាញពី "កថាខណ្ឌ" នៅក្នុងចម្លើយតបនាពេលនេះ ត្រូវបានប្រើប្រាស់សម្រាប់យោងទៅរក កថាខណ្ឌនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

[8] សាលក្រមអង្គជំនុំជម្រះសាលាដំបុង, កថាខណ្ឌ ៥១១ ជើងទំព័រ ១៥២៨ (“ការយោងទីមួយ”)។

ការយោងលើកទីមួយគឺត្រូវបានទាញចេញពីសម្រង់ដូចតទៅនេះ ក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី៖

"នៅវត្តច្រកស្តេច ខ្មែរក្រហមបានប្រកាសតាមមីក្រូ សួររកអ្នកដែលជាមន្ត្រីរបស់របប លន់ នល់ ដោយគេនិយាយថា សូមអញ្ជើញបងប្អូន ដែលធ្លាប់ធ្វើការអ្វីកាលពីមុន គេឲ្យទៅធ្វើការងារចាស់នោះវិញ"[9]។

7. អង្គជំនុំជម្រះសាលាដំបូងក៏បានដកស្រង់ កំណត់ហេតុស្តាប់ចម្លើយរបស់សំ សិទ្ធី នៅពេលពិភាក្សាអំពីភស្តុតាងពាក់ព័ន្ធទាហាន ដែលគោរពតាមការកោះហៅតាមវិទ្យុ និងមីក្រូនោះ៖

"មានភស្តុតាងបង្ហាញថា ទាហាននៃរបបសាធារណរដ្ឋខ្មែរដែលបានធ្វើតាមការអំពាវនាវទាំងនេះ ត្រូវបានយកទៅសម្លាប់ចោល នៅតាមទីកន្លែងផ្សេងៗនៅក្នុង និងនៅជុំវិញទីក្រុងភ្នំពេញ រួមទាំងនៅកន្លែងមួយនៅខាងលិចព្រែកព្នៅ និងនៅទួលគោក ឬ ក៏បាត់ខ្លួនតែម្តង"[10]។

ការយោងលើកទីពីរត្រូវបានដកស្រង់ចេញពី សម្រង់ដូចខាងក្រោមនៃកំណត់ហេតុស្តាប់ចម្លើយ សំ សិទ្ធី៖

"បន្ទាប់ពីចុះឈ្មោះអ្នកដែលបានចូលខ្លួនមក ក្រោយពីការប្រកាសតាមមីក្រូនៅវត្តច្រកស្តេច និងចែកអង្ករឲ្យពួកគាត់រួចមក ប្រជាជនទាំងនោះត្រូវបានបែងចែកជាក្រុមតូចៗ ហើយត្រូវបានពួកខ្មែរក្រហមនាំយកចេញទៅ។ មនុស្សក្នុងក្រុមដែល សំ សិទ្ធី នៅជាមួយនោះ ត្រូវបានគេនាំយកទៅបាញ់សម្លាប់ចោល ប៉ុន្តែ កាលនោះ គាត់ជាកុមារ ហើយបានរស់រានមានជីវិត"[11]។

8. ដោយយោងទៅលើការសម្រេចលើអង្គច្បាប់ ពីអំពើមនុស្សឃាតក្នុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទីមួយ) សាលក្រមអង្គជំនុំជម្រះសាលាដំបូង បានសន្និដ្ឋានថា "ជនរងគ្រោះជាច្រើនដែលត្រូវបានគេកំណត់អត្តសញ្ញាណថា ជាទាហាន ឬ មន្ត្រីរដ្ឋការស៊ីវិលនៃរបបសាធារណរដ្ឋខ្មែរនៅក្នុងអំឡុងពេលជម្លៀស ត្រូវបានគេចាប់យកទៅដោយឡែកដើម្បីសម្លាប់ចោលនៅកន្លែងផ្សេង"[12] ហើយសម្រេចថា "អង្គជំនុំជម្រះយល់ឃើញថា ចារីបានប្រព្រឹត្តដោយមានចេតនាក្នុងការសម្លាប់ជន

[9] សាលក្រមអង្គជំនុំជម្រះសាលាដំបុង, ជើងទំព័រ ១៥២៨ ដកស្រង់ "កំណត់ហេតុស្តាប់ចម្លើយ សំ សិទ្ធី, ឯកសារ E3/5201, ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៨, ទំព័រ ៣, ERN (ភាសាអង់គ្លេស) 00275139"។

[10] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥១១ ជើងទំព័រ ១៥៣០ ("ការយោងទីពីរ")។

[11] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១៥៣០ *ដកស្រង់* "កំណត់ហេតុស្តាប់ចម្លើយ សំ សិទ្ធី, ឯកសារ E3/5201, ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៨, ទំព័រ ៣, ERN (ភាសាអង់គ្លេស) 00275139"។

[12] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៥៣ យោងទៅរកផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទីមួយ), កថាខណ្ឌ ៥០៨, ៥១១, ៥១៣ ដល់៥១៥។

រងគ្រោះទាំងអស់នោះ”[13]។ ហេតុដូច្នេះផ្នែកសម្រេចសេចក្តី លើការសម្រេចពីអង្គច្បាប់ ចំពោះ “ចេតនា” របស់អំពើមនុស្សឃាត ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទីមួយ) គឺពឹងផ្អែកលើការពិភាក្សាអំពីភស្តុតាង ហើយការសន្និដ្ឋានទៅលើអង្គហេតុ ត្រូវបានធ្វើឡើងនៅក្នុងកថាខណ្ឌ ៥០៣, ៥០៨, ៥១១, ៥១៣ ដល់៥១៥, ៤៧៤, ៤៨៦, ៤៩០ និង ៥០៧[14]។

9. ដោយយោងទៅរកសេចក្តីសម្រេចលើអង្គច្បាប់ ចំពោះអំពើអមនុស្សធម៌ដទៃទៀត នៃការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស សាលក្រមអង្គជំនុំជម្រះសាលាដំបូង បានពិចារណាទៅលើការសម្រេចលើអង្គហេតុផ្សេងៗជាច្រើន (កថាខណ្ឌ ៥៦៣) និងការសម្រេចលើបរិបទ (កថាខណ្ឌ ៥៦៤) នៅពេលពិចារណាធាតុផ្សំមួយ ឧទាហរណ៍ “ព្យសនកម្មធ្ងន់ធ្ងរទាំងផ្នែកផ្លូវកាយ និងផ្លូវចិត្ត” (កថាខណ្ឌ ៥៦៥)[15]។ កថាខណ្ឌ ៥១១ មានការយោងទៅរកកំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី ដែលត្រូវបានយោងនៅក្នុងកថាខណ្ឌ ៥៦៤ ដោយពិចារណាថា “ប្រជាជនជាច្រើននៅតែ

---

[13] សាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥៣៖ នាយទាហាន និងមន្ត្រីរដ្ឋការស៊ីវិលជាន់ខ្ពស់ ដែលត្រូវបានគេកំណត់ជាគោលដៅជា សាធារណៈសម្រាប់ការប្រហារជីវិត មុនពេលកាន់កាប់ទីក្រុងភ្នំពេញ ហើយដែលមិនបានរត់គេចខ្លួន ត្រូវបានគេសម្លាប់ចោល។ លើសពីនេះទៀត ជនរងគ្រោះជាច្រើន ដែលត្រូវបានគេកំណត់អត្តសញ្ញាណថា ជាទាហាន ឬ មន្ត្រីរដ្ឋការស៊ីវិលនៃរបបសាធារណរដ្ឋខ្មែរ នៅក្នុងអំឡុងពេលជម្លៀស ត្រូវបានគេចាប់យកទៅដោយឡែកដើម្បីសម្លាប់ចោលនៅកន្លែងផ្សេង។ ចុងក្រោយ ជនរងគ្រោះជាច្រើនដែលបានបដិសេធមិនព្រមចាកចេញពីផ្ទះរបស់ខ្លួននៅក្នុងទីក្រុងភ្នំពេញ ក៏ដូចជាអ្នកដែលមិនបានធ្វើតាមការណែនាំភ្លាមៗរបស់កងទ័ពខ្មែរក្រហម នៅក្នុងពេលធ្វើដំណើរចេញពីទីក្រុង ត្រូវបានគេបាញ់ និងសម្លាប់ចោលនៅនឹងកន្លែង។ មានភស្តុតាងជាច្រើនផងដែរបញ្ជាក់ថា ការសម្លាប់ជនរងគ្រោះ ទាំងនៅក្នុងទីក្រុងភ្នំពេញ និងនៅក្នុងអំឡុងពេលនៃការជម្លៀស គឺធ្វើឡើងដោយគ្មានហេតុផលអ្វីឡើយ។ ដោយសារតែជនរងគ្រោះត្រូវបានបាញ់សម្លាប់ នៅក្នុងចម្ងាយជិត ដូចដែលបានលើកឡើងនេះ ឬ ដោយសារតែមានការខិតខំប្រឹងប្រែងរួមគ្នាដើម្បី កំណត់អត្តសញ្ញាណជនរងគ្រោះ មុនពេលបញ្ជូនពួកគេទៅកន្លែងផ្សេងដើម្បីសម្លាប់ចោលនោះ អង្គជំនុំជម្រះយល់ឃើញថា ចារីបានប្រព្រឹត្តដោយមានចេតនាក្នុងការសម្លាប់ជនរងគ្រោះទាំងអស់នោះ” (ការដកស្រង់ផ្នែកខាងក្នុងត្រូវបានលុបចេញ)។

[14] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១៦៥២ ដល់១៦៥៥។

[15] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៦៥៖ “ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា កាលៈទេសៈដែលប្រកបដោយហិង្សានៅជុំវិញការជម្លៀសប្រជាជនចេញពីទីក្រុង លក្ខខណ្ឌដ៏លំបាកទាំងឡាយដែលអ្នកត្រូវបានជម្លៀសបានជួបប្រទះដែលកាន់តែមានភាពធ្ងន់ធ្ងរដោយសារតែរយៈពេលនៃការធ្វើដំណើររបស់ពួកគាត់ទៅកាន់ស្រុកកំណើតរបស់ខ្លួន និងការធ្វើបាបមកលើពួកគាត់ពីសំណាក់កងទ័ពខ្មែរក្រហម នៅគ្រប់ពេលក្នុងអំឡុងពេលធ្វើដំណើរនេះ បានធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងបានបណ្តាលឲ្យជនរងគ្រោះទទួលរងព្យសនកម្មធ្ងន់ធ្ងរទាំងផ្នែកផ្លូវកាយ និងផ្លូវចិត្ត”។

មិនដឹង អំពីជោគវាសនារបស់សមាជិកគ្រួសាររបស់គេ ដែលត្រូវបានយកចេញទៅបាត់នោះ”[16]។ ហេតុដូច្នេះផ្នែកសម្រេចសេចក្តី របស់ការសម្រេចលើអង្គច្បាប់ អំពីព្យសនកម្មធ្ងន់ធ្ងរទាំងផ្នែកផ្លូវកាយ និងផ្លូវចិត្ត ពាក់ព័ន្ធជាមួយឧក្រិដ្ឋកម្ម នៃអំពើអមនុស្សធម៌ដទៃទៀត នៃការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរបស់មនុស្ស ត្រូវបានពឹងផ្អែកទៅលើការពិភាក្សាអំពីភស្តុតាង និងការសន្និដ្ឋានលើអង្គហេតុ ដែលធ្វើឡើងក្នុងកថាខណ្ឌ ៤៦៤, ៤៦៨, ៤៧១-៤៧៤, ៤៦៥-៤៦៦, ៤៨៦, ៤៨៩-៤៩១, ៤៩៧-៤៩៨, ៤៨៨, ៤៨៧, ៤៩៥-៤៩៦, ៤៦៦, ៤៩២, ៥១១, ៥១៣-៥១៤, និង ៥២២-៥២៤[17]។

10. ទាក់ទងដល់ការសម្រេចលើអង្គច្បាប់ អំពីការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ សាលក្រមអង្គជំនុំជម្រះសាលាដំបូង បានពិចារណាថា “កងទ័ពខ្មែរក្រហមបានប្រឹងប្រែងស្វែងរកសមាជិកទាំងឡាយនៃរបបសាធារណរដ្ឋខ្មែរនៅទូទាំងទីក្រុងភ្នំពេញ នៅតាមប៉ុស្តិ៍ត្រួតពិនិត្យ តាមរយៈការប្រកាសតាមវិទ្យុ ដោយបោកបញ្ឆោតឲ្យទាហានទាំងនោះធ្វើការបង្ហាញខ្លួន មុនពេលធ្វើការចាប់ខ្លួន និងសម្លាប់ពួកគេចោល និងដោយឃើញថា ទាហានទាំងនោះត្រូវបានចាត់ទុកថាជាខ្មាំងនោះ” សម្រេចថា “ការចាប់ខ្លួន និងការសម្លាប់អតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានប្រព្រឹត្តដោយមានចេតនារើសអើងដោយមូលហេតុនយោបាយ”[18]។ ហេតុដូច្នេះ ផ្នែកសម្រេចសេចក្តី អំពីការសម្រេចលើអង្គច្បាប់នៃ “ចេតនា” ក្នុងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ គឺពឹងផ្អែកលើភស្តុតាង និងការសន្និដ្ឋានលើអង្គហេតុ ដែលធ្វើឡើងក្នុងកថាខណ្ឌ ៥០៤ (ជើងទំព័រ ១៥១១) និង កថាខណ្ឌ ៥១១ ដល់៥១៥[19]។

11. ពាក់ព័ន្ធទៅនឹងការសម្រេចលើអង្គច្បាប់ នៃធាតុផ្សំអត្តនោម័តរបស់ ឧក្រិដ្ឋកម្មសម្លាប់រង្គាល អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា៖

> “ពាក់ព័ន្ធនឹងការសម្លាប់អតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលត្រូវបានកំណត់អត្តសញ្ញាណក្រោយពីការផែកឆេរនៅក្នុងទីក្រុងភ្នំពេញ នៅតាមប៉ុស្តិ៍ត្រួតពិនិត្យ ឬ បន្ទាប់ពីការប្រកាសតាមវិទ្យុនោះ អង្គជំនុំជម្រះអាចធ្វើការសន្និដ្ឋានបានដោយសមហេតុផល ដោយផ្អែកទៅ

[16] សាលក្រមអង្គជំនុំជម្រះសាលាដំបុង, កថាខណ្ឌ 564 *ដកស្រង់* ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទីមួយ), កថាខណ្ឌ ៥១១, ៥១៣ ដល់៥១៤។

[17] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១៦៧២ ដល់១៦៨០។

[18] សាលក្រមអង្គជំនុំជម្រះសាលាដំបុង, កថាខណ្ឌ ៥៧១ *ដកស្រង់* ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទីមួយ), កថាខណ្ឌ ៥០៤ (ជើងទំព័រ ១៥១១), ៥១១ ដល់៥១៥។

[19] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបុង, ជើងទំព័រ ១៦៩៣។

លើភ័ស្តុតាងដែលបញ្ជាក់ថា មានប្រតិបត្តិការទ្រង់ទ្រាយធំ មានការរៀបចំ និងគិតទុកជាមុន ដើម្បីសម្លាប់អតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ទោះបីជាមិនមែនថាមន្ត្រីរដ្ឋការទាំងអស់បានជួបប្រទះជោគវាសនាបែបនេះដូចគ្នាក៏ដោយ ។ ដោយយោងទៅលើប្រតិបត្តិការទ្រង់ទ្រាយធំនេះ អង្គជំនុំជម្រះជឿជាក់ថា កងទ័ពខ្មែរក្រហមមានចេតនាសម្លាប់មន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្នុងទ្រង់ទ្រាយធំ ហើយតាមរយៈអំពើទាំងនេះ ពួកគេបានប្រព្រឹត្តការសម្លាប់រង្គាល"[20]។

12. ពាក់ព័ន្ធទៅនិងការសម្រេចលើអង្គហេតុ អំពីសហឧក្រិដ្ឋកម្មរួម សាលក្រមអង្គជំនុំជម្រះសាលាដំបូងសម្រេចថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានគោលនយោបាយកំណត់គោលដៅលើ អតីតអ្នករដ្ឋការសាធារណរដ្ឋខ្មែរ[21]។ ការសម្រេចនេះផ្អែកជាពិសេសលើការសន្និដ្ឋានដែលថា (១) "បន្ទាប់ពីរំដោះ ទាហាន អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និង "ភ្នាក់ងារសម្ងាត់" ត្រូវបានកំណត់គោលដៅ និងស្វែងរកចាប់ខ្លួន និងសម្លាប់ចោល"[22] និង (២) "មុនពេលពួកគេមានឱកាសអនុវត្តផែនការសម្ងាត់នេះ ("ផែនការរដ្ឋប្រហា") អ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរត្រូវបានកំណត់អត្តសញ្ញាណ រួមទាំងនៅតាមកន្លែងត្រួតពិនិត្យផង ត្រូវបានចាប់ខ្លួន អ្នកខ្លះត្រូវបាននាំយកទៅ ហើយអ្នកខ្លះទៀតត្រូវបានសម្លាប់នៅនឹងកន្លែងតែម្តង"[23]។ នៅក្នុងសេចក្តីសន្និដ្ឋានមួយៗ ក្នុងចំណោមសេចក្តីសន្និដ្ឋានទាំងពីរនេះ សាលក្រមអង្គជំនុំជម្រះសាលាដំបូងមាននូវការយោងផ្នែកក្នុងទៅរកកថាខណ្ឌ ៥១១ ដែលក្នុងនោះមានការយោងទៅរក កំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី។ ពាក់ព័ន្ធដល់ចំណុចទី (២) អាចមានការសន្មតដោយសមស្របថា កំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី ត្រូវបានយោងដោយប្រយោល ដើម្បីសន្និដ្ឋានថាអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ ត្រូវបាន "កំណត់អត្តសញ្ញាណ" ហើយ "អ្នកខ្លះត្រូវបានគេយកទៅ" ដោយសារតែគាត់មិនបាននិយាយអំពីចំណុចចំណុចត្រួតពិនិត្យ[24] ការចាប់ខ្លួន[25] និងសម្លាប់នៅនឹងកន្លែង[26]។

---

[20] សាលក្រមអង្គជំនុំជម្រះសាលាដំបុង, កថាខណ្ឌ 561.

[21] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៨១៥ ដល់៨៣៤។

[22] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៨២៣ ជើងទំព័រ ២៥៩៦ យោងទៅរក សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥០៣ ដល់៥១៣ (គូសបញ្ជាក់បន្ថែម)។

[23] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៨៣១ ជើងទំព័រ ២៦២៦ យោងទៅរក សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥០៥, ៥០៧-៥០៩, ៥១១, ៥១៣-៥១៥។

[24] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥១២, ៥១៥។

[25] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥១៣។

[26] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥១៣ ដល់៥១៤។

13. មេធាវីការពារក្តីនួន ជា បានដាក់សារណាបណ្តឹងសាទុក្ខ ប្រឆាំងសាលក្រមក្នុងសំណុំរឿង ០០២/០១ នៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១១[27] ដែលក្នុងសាលក្រមនោះមេធាវីការពារក្តីនួន ជា បានជំទាស់ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង អំពីគោលនយោបាយរបស់ បក្សកុម្មុយនីស្តកម្ពុជា ក្នុងការកំណត់គោលដៅចំពោះទាហាន និងអ្នករដ្ឋការសាធារណរដ្ឋខ្មែរ[28]។

14. សារណាបណ្តឹងសាទុក្ខនួន ជា បានលើកឡើងពីការជំទាស់ប្រឆាំង ការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី នៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ចំពោះការចោទប្រកាន់ពីកំហុសអង្គច្បាប់ និងកំហុសអង្គហេតុ ទាក់ទងទម្រង់នៃការសម្លាប់ទាហាន និងអ្នករដ្ឋការសាធារណរដ្ឋខ្មែរ ដែលមានអត្ថិភាពនៅ ឬក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[29] ដោយចោទប្រកាន់ជាពិសេសថា ភស្តុតាងមិនបាន "គាំទ្រដល់ការសម្រេចទៅលើអង្គហេតុ របស់អង្គជំនុំជម្រះសាលាដំបូងឡើយ"[30] ដែលរួមមាន "អង្គជំនុំជម្រះសម្រេចថា បក្សកុម្មុយនីស្តកម្ពុជាបានសម្លាប់ ទាហានសាធារណរដ្ឋខ្មែរក្នុងមូលដ្ឋានជាទ្រង់ទ្រាយធំ មានការរៀបចំត្រឹមត្រូវ និងដោយចេតនា"[31]។

15. នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ នួន ជា បង្ហាញថា "កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីតែមួយគត់ ដែលមានភស្តុតាងសំខាន់នោះ គឺការស្តាប់ចម្លើយ សំ សិទ្ធី ដែលត្រូវបានពិពណ៌នាលម្អិតពីការដែលគាត់ត្រូវបានគេនាំចេញទៅ ក្នុងអំឡុងពេលនៃការជម្លៀសជាមួយគ្រួសារផ្សេងទៀត ដែលជាប់ពាក់ព័ន្ធនឹងរបបសាធារណរដ្ឋខ្មែរ គាត់ត្រូវបានគេបាញ់ ហើយគួរឲ្យភ្ញាក់ផ្អើល គាត់បានរស់រានមានជីវិត ដោយសារធ្វើពុតជាស្លាប់ និងរត់គេចខ្លួន"[32]។ សារណាបណ្តឹងសាទុក្ខរបស់ នួន ជាបានធ្វើសំណើដោយមានសំអាងហេតុ សុំឲ្យកោះហៅ សំ សិទ្ធី ដោយលើកទឡ្ហីករណ៍ថា "ប្រសិនបើសាក្សីមិនត្រូវបានកោះហៅទេនោះ ការសំអាងទៅលើកំណត់ហេតុ នៃការស្តាប់ចម្លើយរបស់គាត់

---

[27] បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងសាលក្រមសំណុំរឿង ០០២/០១, ឯកសារ **F16**, ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ("សារណាបណ្តឹងសាទុក្ខរបស់ នួន ជា")។

[28] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា, កថាខណ្ឌ ៥២៦ ដល់៥៩៩។

[29] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា, មូលដ្ឋាន ២០៨, កថាខណ្ឌ ៥៨១ ដល់៥៩៩។

[30] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា, កថាខណ្ឌ ៥៩២ ដល់៥៩៦។

[31] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា, កថាខណ្ឌ ៥៩២។ សហមេធាវីនាំមុខកត់សម្គាល់ថាឃ្លា "ទ្រង់ទ្រាយធំ ដោយមានការរៀបចំ និងដោយចេតនា" ត្រូវបានប្រើប្រាស់នៅក្នុងកថាខណ្ឌ ៥៦១ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធការសម្រេចលើអង្គច្បាប់ អំពី "ធាតុផ្សំអត្តនោម័តរបស់ចារី" សម្រាប់ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទីមួយ)។

[32] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា, កថាខណ្ឌ ៥៩៥។

ដោយអង្គជំនុំជម្រះសាលាដំបូង នឹងបង្កើតបានជាកំហុសទាំងអង្គហេតុ និងអង្គច្បាប់"[33]។ សហព្រះរាជអាជ្ញាបានឆ្លើយតបនៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥[34]។ សហមេធាវីនាំមុខមិនឆ្លើយតបទៅនឹងសំណើនេះទេ។

16. នៅថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលសម្រេច កោះហៅ សំ សិទ្ធី តាមការផ្តួចផ្តើមផ្ទាល់ខ្លួន "ដើម្បីប្រយោជន៍យុត្តិធម៌" ដោយសម្រេចថា "អាចនាំទៅដល់ការស្វែងរកការពិត" ដោយចាត់ទុកថាជាការសំខាន់ ក្នុងការស្តាប់ចម្លើយសាក្សីដោយផ្ទាល់[35]។ សំ សិទ្ធីបានមកផ្តល់សក្ខីកម្មនៅថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៥ ក្នុងនាម SCW-3។

## III. ច្បាប់ជាធរមាន

17. តាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូលអាច "ស្វែងរកភស្តុតាងថ្មី" ដើម្បីសម្រេចលើបណ្តឹងសាទុក្ខ តាមការផ្តួចផ្តើមផ្ទាល់ខ្លួន នៅពេលដែលប្រយោជន៍យុត្តិធម៌តម្រូវ ដោយពិចារណាដល់កាលៈទេសៈជាក់លាក់ នៃរឿងក្តី[36]។

18. តាមអត្ថន័យនៃវិធាន ១០៤ស្ទួន នៃវិធានផ្ទៃក្នុង[37] អង្គជំនុំជម្រះតុលាការកំពូលបានពិចារណា ដល់សិទ្ធិអំណាចក្នុងការស្វែងរក "ភស្តុតាងថ្មី" ថាជាកម្មវត្ថុនៃលក្ខខណ្ឌតម្រូវ ក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ ហេតុដូច្នេះក្នុងការអនុវត្តឆន្ទានុសិទ្ធិនេះ អង្គជំនុំជម្រះនិងត្រូវធ្វើការពិចារណាថាតើ ភស្តុតាង "អាចនាំដល់ការស្វែងរកការពិត" ដែរឬយ៉ាងណា[38]។

19. វិធាន ១០៤ស្ទួន នៃវិធានផ្ទៃក្នុង ដោយអាចរួមជាមួយវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក៏ធ្វើឱ្យភស្តុតាងបែបនេះក្លាយជាកម្មវត្ថុនៃលក្ខខណ្ឌតម្រូវ តាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងដែលចែងថា៖

---

[33] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា, កថាខណ្ឌ ៥៩៥។ *សូមមើល ផងដែរ ដូចខាងលើ,* កថាខណ្ឌ ៧៣០។

[34] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១, ឯកសារ **F17/1**, ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥, កថាខណ្ឌ ៦២។

[35] សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ, ឯកសារ **F2/5**, ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៥, កថាខណ្ឌ ២៣។

[36] សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ, ឯកសារ **F2/5**, ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៥, កថាខណ្ឌ ១៧។

[37] វិធាន ១០៤ស្ទួន នៃវិធានផ្ទៃក្នុង៖ "រាល់វិធានដែលត្រូវអនុវត្តនៅអង្គជំនុំជម្រះសាលាដំបូង ត្រូវយកមកអនុវត្តចំពោះអង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីសមស្រប ប្រសិនបើគ្មានបទប្បញ្ញត្តិដោយឡែកណាមួយនោះទេ"។

[38] សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ, ឯកសារ **F2/5**, ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៥, កថាខណ្ឌ ១៧។

“អង្គជំនុំជម្រះអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាង បើយល់ឃើញថា ៖

ក-មិនជាប់ពាក់ព័ន្ធ ឬ ជាការស្នើសុំជាន់គ្នា

ខ-មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ

គ-មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង

ឃ-ច្បាប់មិនអនុញ្ញាត ឬ

ង-មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។

20. វិធាន ៩៣(១) នៃវិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះអាចបង្គាប់ឲ្យធ្វើការស៊ើបអង្កេតបន្ថែម នៅពេលដែលខ្លួនពិចារណាថា “កិច្ចស៊ើបអង្កេតថ្មីគឺជាការចាំបាច់”។ ដូចក្នុងវិធាន ៩៣(២)នៃវិធានផ្ទៃក្នុង ចៅក្រមអង្គជំនុំជម្រះ ក៏ត្រូវស្ថិតនៅក្រោមល័ក្ខខ័ណ្ឌដូចគ្នាទៅនឹងសហចៅក្រមស៊ើបអង្កេតដែរ ហើយអាច ៖ក-ចុះទៅដល់ទីកន្លែងណា ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ច នៃយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា, ខ-ស្តាប់ចម្លើយសាក្សី, គ-ដឹកនាំការឆែកឆេរ, ឃ-ចាប់យកវត្ថុតាង”។

21. វិធាន ២១(១) នៃវិធានផ្ទៃក្នុងចែងថា “ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និង ត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ” ហើយថា “អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី”។ វិធាន ២១(៤) នៃវិធានផ្ទៃក្នុងចែងថា “ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប”។

22. វិធាន ១២ ស្ទួនពីរ (១) នៃវិធានផ្ទៃក្នុងចែងថា “សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវធានាឲ្យមានប្រសិទ្ធិភាពអំពីការរៀបចំ ការតំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ ដែលធ្វើឲ្យមានតុល្យភាពនូវសិទ្ធិរបស់ភាគីទាំងអស់ និងតម្រូវការឲ្យការជំនុំជម្រះប្រព្រឹត្តទៅបានឆាប់រហ័ស ក្នុងបរិបទពិសេសរបស់ អ.វ.ត.ក”។ បន្ថែមលើនេះ តាមវិធាន ១២ស្ទួនពីរ(២) នៃវិធានផ្ទៃក្នុង សហមេធាវីនាំមុខត្រូវមានកាតព្វកិច្ច លើកកំពស់យុត្តិធម៌ និងដំណើរការនីតិវិធីប្រកបដោយភាពត្រឹមត្រូវ និងមានប្រសិទ្ធភាព”។

23. នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ដើមបណ្តឹងរដ្ឋប្បវេណី “ទទួលបានសិទ្ធិជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលមានចែងក្នុងមាត្រា ១៤(១) [នៃកតិកា

រសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ]" ហើយ "មានតួនាទីជាក់លាក់ និងមានកម្រិតនៅក្នុង កិច្ចដំណើរការនីតិវិធី ដូចមានចែងក្នុងវិធានផ្ទៃក្នុង របស់អ.វ.ត.ក"[39]។

## IV. **សារណា**

24. សហមេធាវីនាំមុខសូមឆ្លើយតបទៅនឹងសំណើ ក្នុងនាមក្រុមរួមគ្នារបស់ដើមបណ្តឹងរដ្ឋប្បវេណី តាម កាតព្វកិច្ច លើកកំពស់យុត្តិធម៌ និងដំណើរការនីតិវិធីប្រកបដោយភាពត្រឹមត្រូវ និងមានប្រសិទ្ធិភាព សម្រាប់ជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី[40]។ សហមេធាវីនាំមុខសូមសង្កត់ធ្ងន់ថា ក្នុងពេល កន្លងមកខ្លួនមិនដែលជំទាស់ ទៅនិងសំណើដោយមានសំអាងហេតុ របស់មេធាវីការពារក្តី នួន ជា សុំឱ្យកោះហៅសាក្សីបន្ថែមសម្រាប់បណ្តឹងសាទុក្ខ ហើយជាគោលការណ៍សហមេធាវីនាំមុខ ក៏មិន ដែលជំទាស់សាជាថ្មី ចំពោះការពិចារណាទៅលើភស្តុតាងបន្ថែម ដែលអាចជំរុញដល់ការស្វែងរក ការពិត ដោយអង្គជំនុំជម្រះតុលាការកំពូលឡើយ។ សហមេធាវីនាំមុខពិចារណាថា ការធ្វើសំណើ បែបនេះដើម្បីប្រយោជន៍ដល់កូនក្តីរបស់ពួកគេ គឺជាបុព្វសិទ្ធិរបស់មេធាវីការពារក្តី។ ហេតុដូច្នេះនៅ ក្នុងចម្លើយតបនាពេលនេះ សហមេធាវីនាំមុខមិនបានស្នើសុំដំណោះស្រាយជាក់លាក់ណាមួយ ពីអង្គ ជំនុំជម្រះតុលាការកំពូល ពាក់ព័ន្ធដល់លទ្ធផលនៃសំណើនេះឡើយ ដោយគ្រាន់តែសុំឱ្យអង្គជំនុំជម្រះ ធ្វើការពិចារណាពីការព្រួយបារម្ភណ៍រួម ដែលបានលើកឡើងនៅផ្នែកខាងក្រោម នៅពេលអង្គជំនុំ ជម្រះធ្វើការសម្រេច ទៅលើអង្គសេចក្តីនៃសំណើ។

25. ជាទូទៅដើម្បីភាពងាយស្រួលក្នុងការពិភាក្សា សហមេធាវីនាំមុខសូមធ្វើការញែកចេញពីគ្នា រវាងការ យោងលើកទីមួយ និងការយោងលើកទីពីរ សម្រាប់មូលហេតុថា ដោយសារពាក្យពេចន៍ដែលបាន ប្រើប្រាស់ ក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូវ គឺមានភាពច្បាស់លាស់ណាស់ថា ការយោងលើក ទីមួយ នាំទៅដល់ការសន្និដ្ឋានលើអង្គហេតុដែលថា ឧទាហរណ៍ "នៅប៉ុន្មានថ្ងៃបន្ទាប់ពីជម្លៀស ខ្មែរ ក្រហមបានប្រកាសតាមវិទ្យុ និងតាមមីក្រូនៅតាមកន្លែងជាច្រើនក្នុងទីក្រុងភ្នំពេញថា អ្នករដ្ឋការនៃ របបសាធារណរដ្ឋខ្មែរត្រូវចូលបង្ហាញខ្លួន បង្ហាញពីឋានៈ តួនាទី កាលពីមុនរបស់ខ្លួន និងត្រឡប់ទៅទី ក្រុងភ្នំពេញវិញដើម្បីសហការ ឬ ចូលរួមជាមួយកងទ័ពខ្មែរក្រហម"[41]។ ចំណែកការយោងលើកទី ពីរបង្កើតបានជាការពិភាក្សាលើភស្តុតាង ដែលថាអង្គជំនុំជម្រះសាលាដំបូងបានពិចារណា ពីភាព ពាក់ព័ន្ធសម្រាប់បទចោទនៅចំពោះមុខខ្លួន៖ "មានភ័ស្តុតាងបង្ហាញថា ទាហាននៃរបបសាធារណរដ្ឋ

---

[39] សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលា របស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់សួរដេញដោលសាក្សី SCW-5, ឯកសារ **F26/2/2**, ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥, កថាខណ្ឌ ៧។

[40] វិធាន ១២ស្ទួនពីរ(២) នៃវិធានផ្ទៃក្នុង។

[41] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥១១ ជើងទំព័រ ១៥២៨ ("ការយោងទីមួយ")។

ខ្មែរដែលបានធ្វើតាមការអំពាវនាវទាំងនេះត្រូវបានយកទៅសម្លាប់ចោល នៅតាមទីកន្លែងផ្សេងៗនៅក្នុង និងនៅជុំវិញទីក្រុងភ្នំពេញ រួមទាំងនៅកន្លែងមួយនៅខាងលិចព្រែកព្នៅ និងនៅទួលគោក ឬ ក៏បាត់ខ្លួនតែម្តង"[42]។

26. ជាចុងក្រោយ បើទោះបីជាមានអង្គហេតុដែលថា គុណភាពនិងភាពមិនស៊ីសង្វាក់គ្នា នៃសក្ខីកម្មរបស់ សំ សិទ្ធី ព្រមទាំងអង្គសេចក្តីនៃសំណើសុំបំពេញកិច្ចស៊ើបសួរ នាពេលបន្ទាប់មក បានក្លាយជាវេទិការបន្ថែមសម្រាប់ ក្រុមមេធាវីការពារក្តី នួន ជា ធ្វើការទាមទារនូវអ្វីដែលពួកគេបានធ្វើឡើងរួចរាល់ហើយ នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ពួកគេក៏ដោយ ក៏សហមេធាវីនាំមុខមិនធ្វើការឆ្លើយតប ចំពោះអង្គសេចក្តីនៃបណ្តឹងសាទុក្ខរបស់ពួកគេដែរ។ ការកត់សម្គាល់នានាដែលមាននៅក្នុងផ្នែក IV(ក)(ខ) នៃចម្លើយតបនាពេលនេះ គឺគ្រាន់តែសម្រាប់គោលបំណងនៃការថ្លឹងថ្លែង រវាងការព្រួយបារម្ភរបស់មេធាវីការពារក្តី ធៀបជាមួយផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដូចបានរៀបរាប់ក្នុងផ្នែក VI(គ)។

27. ដោយមិនគិតថាសារណាបណ្តឹងសាទុក្ខរបស់ នួន ជា បង្ហាញដោយមិនត្រឹមត្រូវនូវ ការសម្រេចនានានៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដែលថាបក្សកុម្មុយនីស្តកម្ពុជា សម្លាប់ទាហានសាធារណរដ្ឋខ្មែរ "ក្នុងទ្រង់ទ្រាយធំ ដោយមានការរៀបចំ និងមានចេតនា"[43] សហមេធាវីនាំមុខសូមលើកឡើងថា ផ្នែកជាច្រើននៃការកំណត់លក្ខណៈ និងលក្ខណៈរំជួលចិត្តនៃសំណើ គឺកើតចេញពីសារៈសំខាន់ដែលកំណត់ដោយមិនត្រឹមត្រូវ ដែលមេធាវីការពារក្តី នួន ជា បានកំណត់ទៅលើសក្ខីកម្មរបស់ សំ សិទ្ធី។

**ក. សហជនជាប់ចោទមិនត្រូវបានចោទប្រកាន់ ឬផ្តន្ទាទោសពីបទសម្លាប់រង្គាល ដែលបានរៀបរាប់ដោយ សំ សិទ្ធីទេ**

28. សហមេធាវីនាំមុខសូមបន្ថែមថា សហជនជាប់ចោទមិនដែលត្រូវបានចោទប្រកាន់ ឬផ្តន្ទាទោសនៅអង្គជំនុំជម្រះសាលាដំបូង ពីបទសម្លាប់រង្គាល ដែលបានរៀបរាប់ក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់

---

[42] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥១១ ជើងទំព័រ ១៥៣០ ("ការយោងទីពីរ")។

[43] សហមេធាវីនាំមុខកត់សម្គាល់ថាឃ្លា "ទ្រង់ទ្រាយធំ ដោយមានការរៀបចំ និងដោយចេតនា" ត្រូវបានប្រើប្រាស់នៅក្នុង សាលក្រមអង្គជំនុំជម្រះសាលាដំបូង លើការសម្រេចទាក់ទងធាតុផ្សំអត្តនោម័តរបស់ ការសម្រេចលើអង្គច្បាប់ សម្រាប់ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទីមួយ)។ ការសម្រេចផ្នែកអង្គច្បាប់នេះ ផ្អែកលើការសម្រេចលើអង្គហេតុដែលថា "អតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ ត្រូវបានកំណត់អត្តសញ្ញាណ បន្ទាប់ពីមានការស្រាវជ្រាវនៅក្នុងទីក្រុងភ្នំពេញ នៅតាមកន្លែងត្រួតពិនិត្យជាច្រើន ឬក៏តាមការប្រកាសរបស់វិទ្យុ" (សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៦១)។

សំ សិទ្ធី ឬសក្ខីកម្មរបស់គាត់ឡើយ។ កថាខណ្ឌ ៥១១ ដែលមានការយោងទៅរក កំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី ត្រូវបានដកស្រង់ដើម្បីធ្វើ (១) ការសម្រេចលើអង្គច្បាប់ អំពីចេតនាប្រព្រឹត្តអំពើមនុស្សឃាត[44], (២) ការសម្រេចលើអង្គច្បាប់អំពីធាតុផ្សំនៃព្យសនកម្មធ្ងន់ធ្ងរលើរូបរាងកាយ និងផ្លូវចិត្ត ដោយសារតែកំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី ធ្វើអោយរំជួលចិត្តដល់មនុស្សជាច្រើន ដែលមិនបានដឹងអំពីជោគវាសនា នៃសមាជិកគ្រួសាររបស់ខ្លួន ដែលត្រូវបានគេយកទៅ[45], (៣) ការសម្រេចលើអង្គច្បាប់ អំពីចេតនាក្នុងការរើសអើង ដោយផ្អែកលើមូលដ្ឋាននយោបាយ[46], (៤) ការសម្រេចលើអង្គច្បាប់ អំពីធាតុផ្សំអត្តនោម័តរបស់ការសម្លាប់រង្គាល់, (៥) ការសម្រេចលើអង្គហេតុអំពីគោលនយោបាយ ពាក់ព័ន្ធសហឧក្រិដ្ឋកម្មរួម ក្នុងកម្រិតដែលអ្នករដ្ឋការសាធារណរដ្ឋខ្មែរ ត្រូវបានកំណត់គោលដៅ និងស្វែងរកដើម្បីចាប់ខ្លួន និងសម្លាប់[47] បន្ទាប់ពីត្រូវបាន "កំណត់អត្តសញ្ញាណ" ឬ "នាំយកទៅ"[48]។

29. សាលក្រមអង្គជំនុំជម្រះសាលាដំបូង មិនបានពឹងផ្អែកលើកំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី ដើម្បីធ្វើការសម្រេចលើអង្គហេតុ ពាក់ព័ន្ធអំពើមនុស្សឃាតឡើយ ប៉ុន្តែអង្គជំនុំជម្រះបានពិភាក្សាទៅលើភស្តុតាងរបស់គាត់ នៅពេលពិចារណាថាភស្តុតាងមានភាពពាក់ព័ន្ធ ដល់ការប្រព្រឹត្តិទៅលើអ្នករដ្ឋការ និងទាហានសាធារណរដ្ឋខ្មែរ[49] ហើយនៅពេលបន្ទាប់មកបានពឹងផ្អែកទៅលើភស្តុតាង ដែលមានក្នុងកថាខណ្ឌ ៥១១ ដើម្បីសម្រេចលើអង្គច្បាប់ពាក់ព័ន្ធ ចេតនានៃអំពើមនុស្សឃាត[50]។

---

[44] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៥៣ យោងទៅរកផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទីមួយ), កថាខណ្ឌ ៥០៨, ៥១១, ៥១៣ ដល់៥១៥។

[45] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៦៤ *ដកស្រង់* ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទីមួយ), កថាខណ្ឌ ៥១១, ៥១៣ ដល់៥១៤។

[46] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៧១ *ដកស្រង់* ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទីមួយ), កថាខណ្ឌ ៥០៤ (ជើងទំព័រ ១៥១១), ៥១១ ដល់៥១៥។

[47] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៨២៣ ជើងទំព័រ ២៥៩៦ យោងទៅរក សាលក្រមអង្គជំនុំជម្រះសាលាដំបុង, កថាខណ្ឌ ៥០៣ ដល់៥១៣ (គូសបញ្ជាក់បន្ថែម)។

[48] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៨៣១ ជើងទំព័រ ២៦២៦ យោងទៅរក សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥០៥, ៥០៧ ដល់៥០៩, ៥១១, ៥១៣ ដល់៥១៥។

[49] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥០១ ដល់៥១១។

[50] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៥៣ យោងទៅរកផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទីមួយ), កថាខណ្ឌ ៥០៨, ៥១១, ៥១៣ ដល់៥១៥។

ខ. ការពឹងផ្អែកដោយមានកម្រិតទៅលើ កំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី អំពីគោលនយោបាយនៃការកំណត់គោលដៅ ចំពោះអ្នករដ្ឋការសាធារណរដ្ឋខ្មែរ

30. សាលក្រមអង្គជំនុំជម្រះសាលាដំបូងបានពឹងផ្អែកតិចតួចប៉ុណ្ណោះ ទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី ក្នុងការសន្និដ្ឋានថាមានអត្ថិភាពគោលនយោបាយ កំណត់គោលដៅចំពោះអ្នករដ្ឋការសាធារណរដ្ឋខ្មែរ។ ការនេះបានបង្ហាញច្បាស់ចំនួនពីរដង ដែលកថាខណ្ឌ ៥១១ ត្រូវបានដកស្រង់ (រួមជាមួយកថាខណ្ឌដទៃទៀតចំនួនប្រាំបី) ដើម្បីបង្ហាញថា "អ្នករដ្ឋការសាធារណរដ្ឋខ្មែរ ត្រូវបានកំណត់គោលដៅ និងស្វែងរកដើម្បីចាប់ខ្លួន និងសម្លាប់"[51] ហើយថា "អ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរត្រូវបានកំណត់អត្តសញ្ញាណ រួមទាំងនៅតាមកន្លែងត្រួតពិនិត្យផង ត្រូវបានចាប់ខ្លួនអ្នកខ្លះត្រូវបាននាំយកទៅ ហើយអ្នកខ្លះទៀតត្រូវបានសម្លាប់នៅនឹងកន្លែងតែម្តង"[52]។

31. ការសម្រេចទៅលើអង្គហេតុនៃការកំនត់គោលដៅ ដូចជាថា "អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថាកងទ័ពខ្មែរក្រហមបានកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ហើយថាអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរជាច្រើនត្រូវបានចាប់ខ្លួន ហើយក្រោយមកក៏បានបាត់ខ្លួន ឬ ក៏ត្រូវបានសម្លាប់ចោលនៅប៉ុន្មានថ្ងៃក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥"[53] គឺពឹងផ្អែកទៅលើភស្តុតាងដែលត្រូវបានពិចារណានៅក្នុងកថាខណ្ឌ ៥១២ ដល់៥១៥ ដែលមានភស្តុតាងដែលផ្តល់ឲ្យដោយ ដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់នៅក្នុងសាលសវនាការ អំពីអង្គហេតុដែលជាកម្មវត្ថុនៃការសួរដេញដោល[54]។ សហមេធាវីនាំមុខយោងទៅលើចម្លើយតបរបស់ពួក គេ នៅក្នុងបណ្តឹងសាទុក្ខត្រង់ចំណុចនេះ[55]។

32. ហេតុដូច្នេះតាមរយៈការអានដោយម៉ត់ចត់ ទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង គឺច្បាស់ណាស់ថា កំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី មិនត្រឹមបានពឹងប្រើប្រាស់ឡើយសម្រាប់ការ

---

[51] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៨២៣ ជើងទំព័រ ២៥៩៦ យោងទៅរក សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥០៣ ដល់៥១៣ (គូសបញ្ជាក់បន្ថែម)។

[52] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៨៣១ ជើងទំព័រ ២៦២៦ យោងទៅរក សាលក្រមអង្គជំនុំជម្រះសាលាដំបុង, កថាខណ្ឌ ៥០៥, ៥០៧ ដល់៥០៩, ៥១១, ៥១៣ ដល់៥១៥។

[53] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥១៥ (គូសបញ្ជាក់បន្ថែម)។

[54] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១៥៣១ ដល់១៥៤៤។

[55] ចម្លើយតបរបស់សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ប្រឆាំងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១,ឯកសារ **F17/2**, ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥, កថាខណ្ឌ ៧០ ដល់១០៤។

សម្រេចថា អ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ ត្រូវបានសម្លាប់ផ្អែកលើមូលដ្ឋាន "ជាទ្រង់ទ្រាយធំ ដោយមានការរៀបចំ និងដោយចេតនា" ហើយសំណើគួរត្រូវបានពិនិត្យមើលក្នុងបរិបទនេះ។

33. ក្នុងកម្រិតដែលសាលក្រមអង្គជំនុំជម្រះសាលាដំបូង បានយោងទៅលើកំណត់ហេតុស្ដាប់ចម្លើយរបស់ សំ សិទ្ធី គឺឯកសារដែលត្រូវបានទទួលយក ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ការពឹងផ្អែកគឺតិចតួច ហើយសមស្របតែក្នុងក្របខណ្ឌនៃ បទដ្ឋានពិនិត្យមើលលើបណ្ដឹងសាទុក្ខ ដែលអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក ដោយកត់សម្គាល់ថា កំណត់ហេតុស្ដាប់ចម្លើយមិនបាននិយាយពី អំពើ និងការប្រព្រឹត្តិរបស់សហជនជាប់ចោទឡើយ[56]។

34. ពាក់ព័ន្ធនិងការយោងទីមួយ ដែលសាលក្រមអង្គជំនុំជម្រះសាលាដំបូង ពិតជាបានទាញចេញនូវការសន្និដ្ឋានលើអង្គហេតុ ដូចជាថា "ខ្មែរក្រហមបានប្រកាសតាមវិទ្យុ និងតាមមីក្រូនៅតាមកន្លែងជាច្រើនក្នុងទីក្រុងភ្នំពេញថា អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវចូលបង្ហាញខ្លួន បង្ហាញពីឋានៈ តួនាទី កាលពីមុនរបស់ខ្លួន និងត្រឡប់ទៅទីក្រុងភ្នំពេញវិញ"[57] សក្ខីកម្មផ្ទាល់មាត់របស់គាត់គឺមានភាពស៊ីសង្វាក់គ្នាផ្ទៃក្នុង[58] ហើយស្របគ្នាជាមួយព័ត៌មានរបស់គាត់ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ"[59]

---

[56] សេចក្ដីសម្រេចលើសារណាតាមវិធាន ៩២ របស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី និងឯកសារដទៃទៀត នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ឯកសារ **E96/7**, ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២, កថាខណ្ឌ ២១ ដល់២២។ *សូមមើល ផងដែរ* សេចក្ដីសម្រេចលើការជំទាស់ ភាពអាចទទួលយកបាននៃ កំណត់ហេតុស្ដាប់ចម្លើយសាក្សី ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី ព្រមទាំងប្រតិចារឹកសំណុំរឿង ០០១ ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី, ឯកសារ **E299**, ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣, កថាខណ្ឌ ១៧ ដល់ ១៩។

[57] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥១១ ជើងទំព័រ ១៥២៨ ("ការយោងទីមួយ")។

[58] ប្រតិចារឹក ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៥, ឯកសារ **F1/2.1**, ទំព័រ ១៨៖ "ឆ៖ បន្ទាប់ពីខ្ញុំមកដល់ទីនោះ មានការប្រកាសថា ពួកគេចង់ស្វែងរកអតីតអ្នករដ្ឋការ ដើម្បីឱ្យពួកគេត្រឡប់ទៅធ្វើការវិញ"។ ទំព័រ ១៥៖ "ប្រកាសថាយើងអាចទទួលបានអង្ករ ក្រោយពេលយើងចុះឈ្មោះ ហើយគ្រប់គ្នាអាចត្រឡប់ទៅធ្វើការ តាមតួនាទីមុនរបស់យើង"។ ទំព័រ ១១ ដល់១២៖ "គេបង្ខំខ្ញុំឱ្យចេញពីផ្ទះ ហើយទៅតំបន់ភ្នំ ហើយនៅពេលទៅដល់វត្តច្រកស្ដេច ខ្ញុំបានឮការប្រកាសថា អតីតអ្នករដ្ឋការ ទាហាន ឬសិស្ស អាចទៅយកការចែកអង្ករ ហើយពួកគេអាចត្រឡប់ទៅកន្លែងធ្វើការមុនរបស់ពួកគេ"។ ទំព័រ ១៩៖ "ឆ៖ នៅថ្ងៃនោះ មានមីក្រូ ហើយមានការប្រកាសតាមមីក្រូ រកអតីតទាហាន និងអ្នករដ្ឋការ ហើយការប្រកាសគឺដើម្បីស្វែងរកអតីតអ្នករដ្ឋការ ដើម្បីឱ្យពួកគេអាចទៅបើកអង្ករ ហើយនៅពេលមានការប្រកាសនោះ គេចុះឈ្មោះមនុស្សនៅក្នុងបញ្ជី ហើយគេកុហកយើងទាំងអស់គ្នាថា យើងអាចត្រឡប់ទៅធ្វើការវិញ"។ ទំព័រ ៧៣៖ "គេប្រកាសរកមនុស្សមកចុះឈ្មោះ ថាជាអតីតអ្នករដ្ឋការ ដើម្បីដូរអង្ករ ហើយក្រុមការងាររួមមានពួកប្រដាប់អាវុធ និងឈ្លប"។ ទំព័រ ៧៤៖ "ពួកគេប្រកាសរកអ្នករដ្ឋការ និងទាហាន ឱ្យមកចុះឈ្មោះ ដើម្បីដូរយកអង្ករ ហើយពួកគេត្រូវបានបញ្ជូនត្រឡប់ទៅធ្វើការ នៅតាមតួនាទីមុនរបស់ពួកគេវិញ។ [...] បើតាមអ្វីដែលខ្ញុំឮ គឺថាពួកគេមិនបានស្វែងរកប្រជាជនសាមញ្ញ ឬធម្មតាឡើយ គឺពួកគេស្វែងរកទាហាន និងអ្នករដ្ឋការ"។

35. ពាក់ព័ន្ធទៅនិងការយោងទីពីរ ដែលតាមទស្សនៈរបស់សហមេធាវីនាំមុខ បានបង្កើតជាការពិភាក្សាគ្នាអំពីភស្តុតាង គឺមិនមែនជាការសម្រេចលើអង្គហេតុ ឬការសន្និដ្ឋានលើអង្គហេតុឡើយ ហើយត្រូវបានបន្ថែមថា កម្រិតនៃការពឹងផ្អែកទៅលើ កំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី ដើម្បីធ្វើការសម្រេចលើអង្គហេតុ គឺកម្រិតត្រឹមតែចំណុចណាដែលពាក់ព័ន្ធ គោលនយោបាយជារួមរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលកំណត់គោលដៅចំពោះអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរប៉ុណ្ណោះ។ ដោយមិនបាច់និយាយ ការសម្រេចលើអង្គហេតុនេះ មិនពឹងផ្អែកទៅលើការយោងសូម្បីតែមួយ ចំពោះកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ ប៉ុន្តែជាការយោងទៅលើភស្តុតាង និងការសន្និដ្ឋានលើអង្គហេតុ ដែលធ្វើឡើងនៅក្នុងកថាខណ្ឌ ៥០៣ ដល់៥១៥។ សារណាបណ្តឹងសាទុក្ខរបស់ នួន ជា មិនបានជំទាស់ទៅលើការយោង ឬការពឹងផ្អែកទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី ពាក់ព័ន្ធការសម្រេចលើអង្គច្បាប់ឡើយ។

36. សូម្បីត្រឹមការសន្មតថា ការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល អាចពន្យាហួសពីការជំទាស់ដែលមាននៅក្នុងសារណាបណ្តឹងសាទុក្ខ និងដោយផ្តល់សំអាងហេតុនៅក្នុង សារណាបណ្តឹងសាទុក្ខក៏ដោយ ក៏សហមេធាវីនាំមុខសូមលើកឡើងថា ការជំទាស់ទាំងអស់នេះគួរត្រូវបានពិនិត្យមើល មិនត្រឹមតែក្នុងបរិបទនៃបទដ្ឋាន ពិនិត្យមើលលើបណ្តឹងសាទុក្ខ ដែលកំណត់ថាការសម្រេចលើអង្គហេតុមិនអាចត្រូវបានពិនិត្យមើលដោយត្រួសៗ នៅពេលប្តឹងសាទុក្ខប៉ុណ្ណោះទេ[60] ប៉ុន្តែត្រូវមើលផងដែរក្នុងបរិបទនៃកាលៈទេសៈដូចខាងក្រោម។

**គ. ផលប្រយោជន៍នៃក្រុមរួម**

37. សហមេធាវីនាំមុខធ្វើជាតំណាងក្រុមរួម របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានចំនួនសរុបដល់ទៅ ៣ ៨៦៩នាក់ នៅពេលចេញសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ ភាគច្រើននៃដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ គឺមានវ័យចំណាស់ ហើយបានចូលរួមក្នុងកិច្ចដំណើរការនីតិវិធី តាំងពីឆ្នាំ ២០១០មក។ មួយចំនួនធំនៃដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ បានដាក់ពាក្យសុំតាំងខ្លួនតាំងពីឆ្នាំ ២០០៧ មកម្លេះ។

38. សហមេធាវីនាំមុខ និងដើមបណ្តឹងរដ្ឋប្បវេណីក៏គិតគូរផងដែរ អំពីវ័យចំណាស់របស់ជនជាប់ចោទព្រមទាំងអំពីវិធាន ២៣ស្ទួន នៃវិធានផ្ទៃក្នុង ហើយនិងអង្គហេតុដែលថា មរណភាពរបស់ជនជាប់

---

[59] ឯកសារ E3/5201, ទំព័រ ៣៖ “នៅវត្តច្រកស្តេច ខ្មែរក្រហមបានប្រកាសតាមមីក្រូ រកអ្នករដ្ឋការរបបលន់ នល់ ហើយហៅបងប្អូនដែលធ្លាប់ធ្វើការអ្វីកន្លងមក ឲ្យទៅធ្វើការដដែលវិញ”។

[60] សាលដីកាសំណុំរឿង ឌុច, កថាខណ្ឌ ១៧ ផ្អែកលើសាលដីការឿងក្តី *Furundžija*, កថាខណ្ឌ ៣៧។

ចោទ ក៏នឹងបញ្ចប់នូវកិច្ចដំណើរការនីតិវិធី របស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ប្រឆាំងជនជាប់ចោទនៅអ.វ.ត.ក[61]។

39. សហមេធាវីនាំមុខក៏ដឹងអំពីការពិតដែលថា សាលក្រមអង្គជំនុំជម្រះសាលាដំបូង និងចូលជាស្ថាពរ បន្ទាប់ពីត្រូវបានច្រានចោលនៅក្នុងបណ្ដឹងសាទុក្ខ[62]។ ក្នុងន័យជាមួយគ្នានេះ សហមេធាវីនាំមុខសូមសង្កត់ធ្ងន់ថា ទាំងជនជាប់ចោទ និងជនរងគ្រោះទទួលបានសិទ្ធិ ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ យោងតាមគោលការណ៍ជាមូលដ្ឋានរបស់ អ.វ.ត.ក[63]។ ការធានានូវផលប្រយោជន៍របស់ "ជនជាប់ចោទ និងជនរងគ្រោះ" គឺជាគោលការណ៍ជាមូលដ្ឋានមួយ ក្នុងចំណោមគោលការណ៍ជាមូលដ្ឋាននានារបស់ អ.វ.ត.ក[64]។

40. ជាការច្បាស់ណាស់ថា តម្រូវការសម្រាប់សវនាការដែលឆាប់រហ័ស និងតុល្យភាពនៃសិទ្ធិរបស់ភាគីទាំងអស់ ត្រូវបានទទួលស្គាល់ជាចំហរនៅក្នុងវិធានផ្ទៃក្នុង[65]។ សហមេធាវីនាំមុខសូមសង្កត់ធ្ងន់ថា ដើមបណ្ដឹងរដ្ឋប្បវេណីគោរពដល់ សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ របស់ក្រុមមេធាវីការពារក្ដី តាំងពីពេលចាប់ផ្ដើមសវនាការ រហូតដល់ពេលបណ្ដឹងសាទុក្ខ។ ប៉ុន្តែការអះអាងពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការទទួលបានសាលក្រមក្នុងពេលវេលាសមស្រប ព្រមទាំងភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី ដូចជាជនជាប់ចោទដែរនោះ[66] គឺជាផ្នែកនៃសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលត្រូវបានទទួលស្គាល់ដោយ អង្គជំនុំជម្រះតុលាការកំពូល[67] ហើយដែលមិនសូវមានការចាប់អារម្មណ៍។

---

[61] *សូមមើល ផងដែរ* មាត្រា ៧(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលត្រូវបានដកស្រង់ ក្នុងការបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំង ជនជាប់ចោទ អៀង ធីរិទ្ធ, ឯកសារ **E359/1**, ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៥, កថាខណ្ឌ ១០។

[62] វិធាន ១១១(៦) នៃវិធានផ្ទៃក្នុង។

[63] វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

[64] វិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង។

[65] វិធាន ១២ស្ទួនពីរ(១) នៃវិធានផ្ទៃក្នុង។

[66] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ១៤(១) ចែងថា៖ "បុគ្គលទាំងអស់ស្មើគ្នានៅចំពោះមុខតុលាការ"។

[67] សេចក្ដីសម្រេចលើសំណើសុំបន្ថែមពេលវេលា របស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សម្រាប់សួរដេញដោលសាក្សី SCW-5, ឯកសារ **F26/2/2**, ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥, កថាខណ្ឌ ៧។

41. ជាចុងក្រោយ អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការពឹងផ្អែកទៅលើផ្នែកនៃភស្តុតាង បើទោះបីជាផ្នែកដទៃទៀតនៃភស្តុតាង ពីសាក្សីតែមួយនោះ ត្រូវបានចាត់ទុកថាមិនអាចជឿជាក់បានក៏ដោយ[68]។ ដោយមិនបង្ហាញថា ការពឹងផ្អែកដោយមានកម្រិត នៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ចំពោះការសម្រេចលើអង្គហេតុ និងអង្គច្បាប់ ដោយដកស្រង់កំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី បង្កើតបានជាកំហុសដែលមោឃភាពសាលក្រម ឬអំពីកាលៈទេសៈនៃការមិនអនុវត្តដោយយុត្តិធម៌[69] សហមេធាវីនាំមុខសូមអះអាងថា ការអនុញ្ញាតតាមសំណើ គឺមិនបានគោរពដល់តុល្យភាពនៃសិទ្ធិរបស់ភាគីទាំងអស់ ហើយការនេះនឹងស្រូបយកពេលវេលា និងធនធានរបស់អង្គជំនុំជម្រះ ចំពោះការស្វែងរកការពិត ក្នុងពេលដែលដើមបណ្តឹងរដ្ឋប្បវេណី ក្នុងរង់ចាំសាលក្រម។

## V. សំណើសុំដំណោះស្រាយ

**អាស្រ័យហេតុនេះ** សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមស្នើដោយគោរពដល់អង្គជំនុំជម្រះតុលាការកំពូលមេត្តា៖

(១) ពិចារណាដល់ការព្រួយបារម្ភណ៍ដែលបានបង្ហាញ នៅក្នុងចម្លើយតបបច្ចុប្បន្ន នៅពេលសម្រេចក្នុងការអនុញ្ញាតដល់សំណើ។

ដោយសេចក្តីគោរព

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥ | ពេជ អង្គ<br>សហមេធាវីនាំមុខជាតិ | ភ្នំពេញ | |
| | Marie GUIRAUD<br>សហមេធាវីនាំមុខអន្តរជាតិ | ភ្នំពេញ | |

[68] សាលដីការឿងក្តី *Čelebići*, កថាខណ្ឌ ៤៩៧។ សាលដីការឿងក្តី *Kupreškić*, កថាខណ្ឌ ១៥៦។ សាលដីការឿងក្តី *Musema*, កថាខណ្ឌ ៨៩។

[69] វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។